# ពិធីការសំរាប់សេវាកម្មដឹកជញ្ជូន ឬឆាតធើខ្នាតតូច: ឧបសម្ព័ន្ធ C

**ការធ្វើបច្ចុប្បន្នភាពថ្មីៗ 1/26/21:**

- បានលើកលែងបំរាមច្បាប់ស្នាក់នៅផ្ទះ និងច្បាប់ដាក់កំហឹតអោយស្នាក់នៅផ្ទះមានកំណត់ នៅត្រឹមថ្ងៃទី ១/២៥/២១។ ក្រុងឡុងប៊ីឆគឺដាក់អោយស្ថិតនៅចំណាត់ថ្នាក់ពណ៌ស្វាយ ក្រោមផែនការមេរបស់រដ្ឋ ចំពោះសេដ្ឋកិច្ចដែលមានសុវត្ថិភាពជាងមុន។ បទប្បញ្ញត្តិដែលបានធ្វើបច្ចុប្បន្នភាព ទាក់ទងនឹងអាហារ។ បានដកចេញនូវចំនួនម៉ោងដែលបានដាក់កំណត់ នៃប្រតិបត្តិការដែលតម្រូវឱ្យមាន នៅក្រោមច្បាប់ដាក់កំហឹតអោយស្នាក់នៅផ្ទះមានកំណត់។ ការផ្លាស់ប្តូរនានា បានរំលេចអោយឃើញជាពណ៌លឿង។

ពិធីការនេះ នឹងត្រូវបានបំពេញដោយសេវាកម្មដឹកជញ្ជូន ឬឆាតធើខ្នាតតូច, រួមបញ្ចូលទាំង, ទូកជួលនេសាទត្រី, និងមគ្គុទេសទេសចរណ៍ក្រុមតូច។ បន្ថែមពីលើលក្ខ័ណ្ឌដែលបានដាក់លើប្រតិបត្តិការទាំងអស់នេះ ដោយមន្ត្រីសុខាភិបាលរដ្ឋ សំរាប់ប្រតិបត្តិការកំសាន្តសប្បាយនៅខាងក្រៅ, ដែលមានឬមើលឃើញនៅលើគេហទំព័រ https://covid19.ca.gov/industry-guidance/,, អាជីវកម្មនានា ក៏ត្រូវគោរពតាមលក្ខ័ណ្ឌដែលបានដាក់ចេញ នៅក្នុងពិធីការនានាសំរាប់ការផ្តល់នូវសេវាកម្មជួលឧបករណ៍ក្រៅផ្ទះនេះផងដែរ។ ពិធីការនេះ ត្រូវតែបានអនុវត្ត និងបានបិទប្រកាស ឬផ្សាយមុនពេលការធ្វើប្រតិបត្តិការ ។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថានឹងពិនិត្យមើលលើគេហទំព័រ ឡុងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំដើម្បីទទួលបានព័ត៌មានថ្មីៗនេះ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក

(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា

(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង

(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

**សេវាកម្មដឹកជញ្ជូន ឬឆាតជើខ្នាតតូចទាំងអស់ ត្រូវអនុវត្តនូវរាល់វិធានការណ៍នានាដែលអាចអនុវត្តបាន ដែលមានរាយខាងក្រោម ហើយត្រៀមក្នុងការពន្យល់អំពីមូលហេតុអ្វី បានជាវិធានការណ៍ណាមួយ ដែលមិនត្រូវបានអនុវត្តនោះ មិនអាចអនុវត្តបាន។**

**ឈ្មោះអាជីវកម្ម:** ______________________________

**អាស័យដ្ឋានកន្លែង:** ______________________________

**A. ការដាក់កំរឹត ចំពោះការជួល**

☐ ចំនួនមនុស្សនៅលើកប៉ាល់ ត្រូវបាន កំណត់ ឬកំរឹតចំពោះគ្រួសារតែមួយ និងបុគ្គលិក/នាវិក, ប៉ុន្តែមិនមានករណីណាមួយ មិនអោយមានចំណុះ/សមត្ថភាពច្រើនជាង ៥០% នៃចំនួនអតិបរមារបស់នាវានោះឡើយ។

ចំនួនអតិបរិមានៃមនុស្សនៅក្នុងគ្រឹះស្ថាន/កន្លែងនេះ ត្រូវបានកំណត់ត្រឹមចំនួន: ____________________

☐ អតិថិជនតម្រូវអោយពាក់គម្របមុខគ្រប់ពេលវេលាទាំងអស់ ក្នុងកំឡុងពេលដែលនៅទីកន្លែងនោះ និងកំឡុងពេលនៅលើកប៉ាល់។ ការបិទគម្របមុខក្រណាត់ មិនគួរត្រូវពាក់អោយកុមារក្មេងៗ ដែលមានអាយុក្រោម ២ ឆ្នាំឡើយ, អ្នកណាម្នាក់ ដែលមានស្ថានភាពសុខភាព, ស្ថានភាពសុខភាពផ្លូវចិត្ត, ឬពិការភាព ដែលរារាំងពួកគេ មិនអាចអោយពាក់គម្របមុខបាន, ឬបើមិនដូច្នេះទេ ពួកគេមិនអាចដោះចេញនូវម៉ាស់ ឬគម្របមុខបានឡើយ ប្រសិនបើគ្មានជំនួយទេនោះ។

☐ ការឃ្លាតឆ្ងាយរាងកាយពីគ្នា ដែលមានចំងាយយ៉ាងហោចណាស់ ៦ ហ្វីត ត្រូវតែរក្សាអោយបានរវាង (១)បុគ្គលិក/នាវិក និង អតិថិជន និង (២) រវាងសមាជិកនៃគ្រួសារផ្សេងៗគ្នា។

☐ នៅពេលមនុស្សស្លៀកសំលៀកបំពាក់ ដោយមានមួកសុវត្ថិភាព, ពាក់ឧបករណ៍, ខោអាវការពារ, អាវពោងសុវត្ថិភាព ឬរបស់របរផ្សេងៗ, កម្មករគួរតែរក្សានូវគំលាតរាងកាយ។ នៅកន្លែងដែលអាចធ្វើទៅបាន, កម្មកគួរតែបង្ហាញពីរបៀបស្លៀកពាក់និងដោះចេញនូវសំភារៈទាំងអស់នោះវិញឱ្យបានត្រឹមត្រូវ ជាជាងបំពានឬមិនគោរពទៅតាមគំលាតរាងកាយពីគ្នា ដើម្បីទៅជួយ។

☐ ផ្ទៃនានាដែលប៉ះពាល់ខ្ពស់ ឬច្រើន និងតំបន់រួមនៃនាវា និងរបស់របរនីមួយៗនៃឧបករណ៍ ដែលត្រូវបានជួល ត្រូវតែសំអាត ឬជូតជំរះទាំងស្រុង ដោយប្រើថ្នាំសម្លាប់មេរោគដែលមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺ COVID-19 បន្ទាប់ ពី

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

ការប្រើប្រាស់ម្តងៗរួច។

- ☐ ចំនួនបុគ្គលដែលត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ក្នុងទីធ្លាខាងក្នុងនៃនាវា ដូចជាកាប៊ីន, នឹងត្រូវបានកំណត់ដើម្បី អនុញ្ញាតិ អោយមានគំលាតឆ្ងាយរាងកាយពីគ្នា ៦ ហ្វីត ឬច្រើនជាងនេះ។
- ☐ ផ្ញើអនាម័យដៃ (ជាមួយនឹង យ៉ាងហោចណាស់មានជាតិអាល់កុល ៦០%) និង/ឬ កន្លែងលាងដៃ រួមមានសាប៊ូ, ទឹក និងក្រដាសជូត ត្រូវតែរៀបចំអោយមាន សម្រាប់អតិថិជននៅលើនាវា។
- ☐ និយោជិក ត្រូវបានគេចាត់ចែងអោយសំឡាប់មេរោគចំពោះឧបករណ៍ជួល និងនាវា នៅចន្លោះការប្រើប្រាស់។
- ☐ ផ្លាកសញ្ញាណែនាំ ត្រូវបានបិទផ្សាយលើនាវា ទាក់ទងនឹងការឃ្លាតឆ្ងាយរាងកាយពីគ្នា។

**B. ការដាក់កំរឹត ចំពោះកន្លែង & ការដឹកជញ្ជូន/ឆាតធើ**

- ☐ អតិថិជនតម្រូវអោយពាក់គម្របមុខគ្រប់ពេលវេលាទាំងអស់ ក្នុងកំឡុងពេលដែលនៅទីកន្លែងនោះ និងកំឡុងពេលនៅលើកប៉ាល់។ ការបិទគម្របមុខក្រណាត់ មិនគួរត្រូវពាក់អោយកុមារក្មេងៗ ដែលមានអាយុក្រោម ២ ឆ្នាំឡើយ, អ្នកណាម្នាក់ ដែលមានស្ថានភាពសុខភាព, ស្ថានភាពសុខភាពផ្លូវចិត្ត, ឬពិការភាព ដែលរារាំងពួកគេ មិនអាចអោយពាក់គម្របមុខបាន, ឬបើមិនដូច្នេះទេ ពួកគេមិនអាចដោះចេញនូវម៉ាស់ ឬគម្របមុខបានឡើយ ប្រសិនបើគ្មានជំនួយទេនោះ។
- ☐ ឧបករណ៍ជួលត្រូវតែមាននៅលើឆាតធើ ឬធ្វើអោយមាន ជាស្រេចសម្រាប់អតិថិជន ដោយអនុលោមទៅតាម ពិធីការសេវាកម្មជួលឧបករណ៍ក្រៅផ្ទះ<br>(ឧបសម្ព័ន្ធ D)។
- ☐ ផ្លាកសញ្ញាណែនាំ និងព័ត៌មាន ត្រូវបានបិទផ្សាយនៅគ្រប់កន្លែងខាងក្រៅទាំងអស់ ទាក់ទងទៅនឹងការគ្រប់គ្រងការឆ្លង, ការឃ្លាតឆ្ងាយរាងកាយពីគ្នា និងការប្រើប្រាស់គំរបមុខ។
- ☐ ជូនដំណឹងដល់អតិថិជន អំពីពិធីការសុវត្ថិភាពទាំងអស់ ជាមុន។
- ☐ ទាមទារអោយមានការកក់ ហើយអតិថិជន ត្រូវបានលើកទឹកចិត្តអោយបង់ប្រាក់ជាមុន ដោយប្រើកាតដេប៊ីត/ក្រេឌីត នៅពេលកក់។
- ☐ ការបង់ថ្លៃឈ្នួលនៅនឹងកន្លែង ត្រូវបានធ្វើឡើងពីទ្វារខាងក្រៅ បែរមុខទៅរកកន្លែងចាប់ផ្តើមដែលមានស្រាប់ ឬពីតុកត់ឈ្មោះចូល នៅខាងក្រៅទីកន្លែង។ សញ្ញាសំគាល់ចម្ងាយ ៦ ហ្វីត នៃការឃ្លាតឆ្ងាយរាងកាយពីគ្នា ត្រូវបានតំឡើង ដើម្បីអោយអតិថិជនទាំងឡាយ ដឹងអំពីកន្លែងដែលត្រូវរង់ចាំបង់ប្រាក់។ ការទូទាត់ដោយគ្មានការប៉ះពាល់ ឬកាន់, បានត្រូវប្រើ នៅពេលដែលអាចធ្វើទៅបាន។
- ☐ លើកទឹកចិត្តអោយមានការទូទាត់ជាអំណោយ, កាតដេប៊ីត ឬកាតក្រេឌីត។
- ☐ ចំងាយរាងកាយ រវាងនិយោជិក និងអតិថិជនបានត្រូវបង្កើនឡើង (ឧទាហរណ៍ របាំងបែងចែក, កញ្ចក់បាំងនៅតាមចំណុច

ទីតាំងលក់)។

- ការគូសសញ្ញាចំណាំ ឬការកំណត់ព្រំដែននានា ត្រូវបានបង្កើតឡើង ដើម្បីបង្កើតជារបាំងដែលមានចម្ងាយ ៦ ហ្វីត ដើម្បីកាត់បន្ថយនូវទំនាក់ទំនងជិតស្និទ្ធ រវាងនិយោជក និងសាធារណៈជន។
- ទឹកលាងដៃសម្លាប់មេរោគ, សាប៊ូ និងទឹក ឬ ថ្នាំ ឬវត្ថុ/ជូតសំឡាប់មេរោគ ដែលមានប្រសិទ្ធិភាព ត្រូវដាក់អោយមានសំរាប់អោយប្រើ ចំពោះអតិថិជន នៅឯ ឬនៅក្បែរច្រកចូលនីមួយៗ ឆ្ពោះទៅកាន់កន្លែង នៅតាមរទេះភេសជ្ជៈ និងស្ថានីយ៍/កន្លែងអាហារនានា និងបន្ទប់ទឹកទាំងឡាយ, និងចំណុចទំនាក់ទំនងសំខាន់ៗផ្សេងទៀត។
- ការកក់ទុក គឺមិនតិចជាង ១០ នាទី ពីគ្នាឡើយ។ អតិថិជនទាំងអស់ ត្រូវបានលើកទឹកចិត្ត អោយចូលមកកាន់កន្លែងនេះ មិនលើសពី ១០ នាទី មុនពេលពេលវេលាដែលរំពឹងថា នឹងចាប់ផ្តើមឆាតធើ។
- ធុងសំរាម គឺគ្មានការប៉ះពាល់។ ដកគំរបចេញ ប្រសិនបើមាន។
- រាល់បន្ទប់ទឹកទាំងអស់ ត្រូវថែទាំលាងសំអាត និងសំឡាប់មេរោគអោយបានញឹកញាប់។ ទ្វារត្រូវបានបើកចំហរ នៅពេលដែលអាចធ្វើបាន ដើម្បីកាត់បន្ថយនូវការប៉ះពាល់ដៃ ឬផ្ទៃទ្វារ។
- ការលក់រាយ ត្រូវតែអនុវត្តតាម ឬប្រកាន់ខ្ជាប់តាមពិធីការឃ្លាតឆ្ងាយរាងកាយពីគ្នា នៃហាងលក់រាយ។ ទ្វារទាំងអស់នៅកន្លែង ឬតាមទីតាំង ត្រូវបានបើកចំហរ នៅពេលណាដែលអាចធ្វើទៅបាន។
- អតិថិជន តម្រូវអោយចាកចេញពីទ្រព្យសម្បត្តិភ្លាមៗ នៅពេលម៉ោងពេលឆាតធើរបស់ពួកគេបានបញ្ចប់។ មិនអនុញ្ញាតអោយមានការជួបជុំគ្នា ឬបើកបរតកន្ទុយជីតៗគ្នា នៅក្នុងកន្លែងចតរថយន្តឡើយ។
- ការអប់រំ ឬការពន្យល់អំពីការប្រើប្រាស់ឧបករណ៍ជួល ឬការណែនាំអំពីសុវត្ថិភាពសម្រាប់ឆាតធើ ត្រូវតែធ្វើឡើងតាមវីឌីអូ ឬបុគ្គលិកត្រូវតែមានចម្ងាយ ៦ ហ្វីត ពីអតិថិជនទាំងឡាយ។
- ពិធីការនេះត្រូវបានបិទផ្សាយនៅទីតាំងមួយ ដែលអាចមើលឃើញដោយនិយោជិក និងសាធារណៈជន។

## C. អាហារ និងភេសជ្ជៈ

- ភោជនីយដ្ឋានដែលបរិភោគខាងក្នុង, បារ, អាហារសម្រន់, និងសម្បទានផ្សេងទៀត ត្រូវតែដំណើរការស្របតាមបទបញ្ជា និងការណែនាំបច្ចុប្បន្ន សម្រាប់ភោជនីយដ្ឋាននានា នៅក្នុងពិធីសារភោជនីយដ្ឋាន។
- គួរតែត្រូវបិទនូវស្ថានីយ៍អាហារដែលផ្តល់សេវាកម្មដោយខ្លួនឯងទាំងអស់ រួមទាំងម៉ាស៊ីនធ្វើកាហ្វេ, ក្បាលរ៉ូប៊ីណេទឹកសូដា ឬប្រដាប់ចំហុយ។
- នៅពេលដែលអាចធ្វើទៅបាន អតិថិជន និងភ្ញៀវគួរតែបញ្ជាទិញមុខទំនិញតាមអ៊ិនធរណេត ឬតាមទូរស័ព្ទ និងអាហារគួរតែបានរៀបចំរួចជាស្រេចដើម្បីអោយគេមកទទួលយក។ ត្រូវតែមាននូវអាហារសម្រន់ដើរឆ្លងកាត់ ឬសេវាកម្មសម្បទាន សម្រាប់

ការជ្រើសរើសយក របស់ដែលបានបញ្ជាទិញជាមុន។ ប្រសិនបើការបញ្ជាទិញជាមុនមិនមានទេនោះ, ត្រូវធានាថាភ្ញៀវ រក្សាបាននូវគំលាតរាងកាយពីគ្នា នៅពេលបញ្ជាទិញទំនិញ។

- អាហារសម្រន់ និងអ្នកទទួលអាហារសម្បទាន គួរតែលក់ទំនិញខ្ចប់ទុកមុន និងខ្ចប់ដាច់ៗដោយឡែក នៅពេលណាដែលអាចធ្វើទៅបាន។ រុំគ្រឿងប្រាក់ ឬប្លាស្ទិកជាលក្ខណៈបុគ្គលដាច់ដោយឡែក នៅក្នុងកន្សែងក្រដាស ដើម្បីជៀសវាងកុំអោយមនុស្សមកយកពួកគេចេញពីក្រុមឬចង្កោមនៃប្រដាប់ប្រដាប្រើប្រាស់ពីក្នុងកន្ត្រក, ពែង, ឬប្រអប់ឡើយ។
- ហាមឃាត់នូវការរៀបចំផតឡាក់ ឬព្រឹត្តិការណ៍ បរិភោគអាហារ និងការផឹកស៊ីតាមបែបគ្រួសារ ស្រដៀងៗគ្នាដែលបង្កើនហានិភ័យ នៃការចម្លងរោគទៅវិញទៅមក។
- 

## D. ពិធីការ សំឡាប់មេរោគ

- ចំណុចនៃអេក្រង់ស្កាននីយ៍/ម៉ូនីទ័រលក់ ត្រូវបានសំឡាប់មេរោគបន្ទាប់ពីប្រតិបត្តិការរួចម្តងៗ ជាមួយនឹងថ្នាំសំលាប់មេរោគដែលមានប្រសិទ្ធភាពប្រឆាំងនឹងជំងឺ COVID-19។
- ធ្វើការសំអាត ឬជូតជំរះ កន្លែងដែលប៉ះពាល់ខ្ពស់ ឬច្រើន អោយបានទៀងទាត់។
- ខោនធើសាធារណៈ និងបង្អួចសេវាកម្មនានា ត្រូវបានធ្វើអនាម័យអោយបានញឹកញាប់ ជាមួយនឹងថ្នាំសំឡាប់មេរោគដែលមានប្រសិទ្ធិភាព ប្រឆាំងជំងឺ COVID-19។
- ធ្វើការសំឡាប់មេរោគចោលនូវរាល់ផតចលទូទាត់, ប៊ិច និងដែកចារទាំងអស់ បន្ទាប់ពីការប្រើប្រាស់ម្តងៗ។
- និយោជិកបានត្រូវចាត់ចែងអោយ ធ្វើអនាម័យនៅតាមផ្ទៃដែលមានការប៉ះពាល់ច្រើនអោយបានញឹកញប់។
- របស់របរនីមួយៗនៃឧបករណ៍ដែលបានជួល ត្រូវតែសំអាត ឬជូតជំរះ ទាំងស្រុងជាមួយនឹងថ្នាំសម្លាប់មេរោគដែលមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 បន្ទាប់ពីការប្រើប្រាស់រួចម្តងៗ។
- និយោជិកបានត្រូវចាត់ចែងអោយ ធ្វើអនាម័យឧបករណ៍ជួល នៅចន្លោះពេលប្រើប្រាស់។
- ធ្វើអនាម័យដៃ (ជាមួយនឹង យ៉ាងហោចណាស់មានជាតិអាល់កុល ៦០%), សាប៊ូ នឹងទឹក ឬថ្នាំសំឡាប់មេរោគមានប្រសិទ្ធិភាព ប្រឆាំងជំងឺ COVID-19 ដែលត្រូវតែរៀបចំអោយមាននៅតាមទីសាធារណៈ ជាទីដែលនិយោជិកទាំងឡាយមានអន្តរះកម្ម ជាមួយនឹងសមាជិកសាធារណៈជន។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

## E. ពិធីការ និយោជិក

- ☐ និយោជិកដែលមានទំនាក់ទំនងជាមួយអ្នកដទៃត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ នូវកម្របមុខសមរម្យដែលគ្របច្រមុះ និងមាត់។ គម្របមុខ គឺត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ លើកលែងតែនិយោជិកកំពុងធ្វើការនៅក្នុងយានយន្ត, ការិយាល័យ ឬបន្ទប់តែម្នាក់ឯង។ និយោជិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេ ដែលថាពួកគេមិនត្រូវពាក់គម្របមុខ គួរតែពាក់ខែលការពារមុខដោយប្រើក្រវ៉ាត់នៅលើគែមខាងក្រោម, អោយត្រូវ ឬអនុលោមទៅតាមសេចក្តីណែនាំរបស់រដ្ឋ, ប្រសិនបើលក្ខ័ណ្ឌរបស់ពួកគេអាចអោយធ្វើដូច្នេះបាន។ តម្រូវអោយមានទំពក់ ឬប្រដាប់ជួយបិទអោយសមល្មមសមនៅក្រោមចង្កា។ មិនត្រូវប្រើម៉ាស់ ដែលមានវ៉ាល់/សន្ទះមួយផ្លូវ នោះឡើយ។
- ☐ បង្កើតឡើងនូវពេលវេលាចាប់ផ្តើមធ្វើការ និងការផ្លាស់ប្តូរវេនបន្តបន្ទាប់គ្នា សម្រាប់បុគ្គលិក ដើម្បីកំណត់ចំនួនបុគ្គលិកនៅនឹងកន្លែង, នៅឯការប្រជុំក្រុម, នៅឯពេលសំរាកអាហារថ្ងៃត្រង់ និងកំឡុងពេលចេញដំណើរពីធ្វើការ។ គ្មាននរណាម្នាក់ ត្រូវបានអនុញ្ញាតិអោយប្រមូលផ្តុំជាក្រុមឡើយ។
- ☐ ការប្រជុំបុគ្គលិក ត្រូវបានធ្វើឡើងនៅទីវាលបើកចំហរ ដើម្បីរក្សានូវគំលាតឆ្ងាយរាងកាយពីគ្នា។
- ☐ មិនអនុញ្ញាតអោយភ្ញៀវ ឬអ្នកតំណាងលក់ នៅលើ ឬនៅក្នុងកន្លែងឡើយ។ នេះរួមបញ្ចូលទាំង អ្នកចែកចាយខាងក្រៅ និងអ្នកតំណាងក្រុមហ៊ុនផលិតទាំងឡាយ។ ការប្រជុំ ត្រូវបានធ្វើឡើងតាមទូរស័ព្ទ, ហ្ស៊ូម (zoom) ឬវេទិកានិម្មិតផ្សេងៗ។
- ☐ តំរូវ និងអនុញ្ញាតិអោយបុគ្គលិកមានពេលវេលាគ្រប់គ្រាន់ ដើម្បីលាងសំអាត ឬធ្វើអនាម័យដៃរបស់ពួកគេ រៀងរាល់ ៣០ នាទីម្តង ឬទៅតាមតម្រូវការ ប្រសិនបើមានការផ្តល់អោយនូវស្រោមដៃ។ កន្លែងបន្ទប់ទូរចាក់សោរដាក់ឥវ៉ាន់ ត្រូវបានសម្អាតអោយអស់នូវរបស់របរផ្ទាល់ខ្លួន។ ឯកសណ្ឋានបន្ថែម, ប្រដាប់ប្រដារ និងរបស់របរផ្ទាល់ខ្លួនទាំងអស់ អាចត្រូវបានរក្សាទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន នៅនឹងកន្លែង។ មិនមានការអនុញ្ញាតិអោយរក្សាទុក នូវរបស់របរផ្ទាល់ខ្លួន នៅនឹងកន្លែងឡើយ។
- ☐ ការប្រើប្រាស់ របស់របរប្រើប្រាស់ទូទៅនៅបន្ទប់សំរាក (ឧទាហរណ៍ ប៉ាន់កាហ្វេ, ម៉ាស៊ីនលក់, ទូរទឹកកក និងមៃក្រូវ៉េវ) ត្រូវបានផ្អាក។ ម៉ាស៊ីនធ្វើអោយត្រជាក់ផ្ទាល់ខ្លួន ត្រូវបានណែនាំសម្រាប់ពេលញុំាអាហារ/ភេសជ្ជៈផ្ទាល់ខ្លួន ហើយគួរតែទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន។
- ☐ កន្លែងសសំរាក និងអាហារថ្ងៃត្រង់ទីពីរ ត្រូវបានបង្កើតឡើង ប្រសិនបើអាចធ្វើទៅបាន ដើម្បីអនុញ្ញាតិអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នា បានកាន់តែទូលាយជាងមុន។
- ☐ គណៈគ្រប់គ្រងនឹងកំណត់នូវគោលការណ៍ណែនាំនានា សម្រាប់ការសម្អាតកន្លែង យ៉ាងហោចណាស់បីដងក្នុងមួយថ្ងៃ; (ពេលព្រឹក បន្ទាប់ពីការមកដល់របស់បុគ្គលិក, និងក្រុមចាកចេញទៅកន្លែង បន្ទាប់ពីម៉ោងអាហារថ្ងៃត្រង់,

និងនៅចុងបញ្ចប់នៃវេនការងារ នៅពេលដែលបុគ្គលិកគ្រប់រូប បានចាកចេញពីការងារនៃថ្ងៃនោះ ហើយផ្តោតលើចំណុចដែលបានប៉ះពាល់ទាំងអស់ (កន្លែងមូលកាន់តាមមាត់ទ្វារ, បន្ទប់ទឹក, តុ, កៅអី, ស្នូកផ្ទុកទឹក, កុំព្យូទ័រ/ក្តារចុច ។ល។) កន្លែងដែលប៉ះពាល់ច្រើន អាចត្រូវការនូវការសំអាតអោយបានញឹកញាប់។

- និយោជិកទាំងអស់ ត្រូវបានរំលឹកអោយប្រកាន់ខ្ជាប់នូវសកម្មភាពការពារផ្ទាល់ខ្លួននានា ជារួមមាន៖
    - ស្នាក់នៅផ្ទះ នៅពេលដែលអ្នកឈឺ។ ស្នាក់នៅផ្ទះយ៉ាងហោចណាស់ ៣ ថ្ងៃ (៧២ ម៉ោង) បន្ទាប់ពីការជាសះស្បើយ, ដែលមានន័យថា គ្រុនក្តៅរបស់អ្នកបានត្រូវដោះស្រាយ ដោយមិនចាំបាច់ប្រើថ្នាំបន្ថយកំដៅទេ ហើយវាមានភាពប្រសើរឡើង នៃរោគសញ្ញាផ្លូវដង្ហើមនានារបស់អ្នក (ឧទាហរណ៍., ក្អក, ដង្ហើមខ្លី ឬដង្ហក់), និងយ៉ាងហោចណាស់ ១០ ថ្ងៃបានកន្លងផុតទៅ តាំងតែពីរោគសញ្ញាដំបូងរបស់អ្នក បានបង្ហាញចេញមក។
    - លាងដៃរបស់អ្នកអោយបានញឹកញាប់ ជាមួយសាប៊ូ និងទឹក យ៉ាងហោចណាស់ ២០ វិនាទី។ ប្រសិនបើមិនមានសាប៊ូ និងទឹកទេនោះ, សូមប្រើទឹកលាងដៃអនាម័យដែលមានជាតិអាល់កុល យ៉ាងហោចណាស់ ៦០%។ លាងដៃរបស់អ្នក មុនពេលញ៉ាំអាហារ, បន្ទាប់ពីប្រើបន្ទប់ទឹករួច និងក្រោយពេលក្អក និងកណ្តាស់។
    - ខ្ទប់ក្អក និងកណ្តាស់របស់អ្នក ជាមួយនឹងក្រដាសស្តើង ហើយបន្ទាប់មក បោះក្រដាសស្តើងនោះ ចោល ហើយសម្អាតដៃរបស់អ្នកភ្លាមៗ។ ប្រសិនបើអ្នកមិនមានក្រដាសស្តើងទេ សូមប្រើកែងដៃរបស់អ្នក (មិនមែនដៃរបស់អ្នកទេ)
    - កុំប៉ះពាល់មាត់, ភ្នែក, ច្រមុះរបស់អ្នក ដោយដៃដែលមិនទាន់លាងសំអាត។
    - ជៀសវាងការទំនាក់ទំនង ជាមួយមនុស្សឈឺ។
    - ជៀសវាងការចែករំលែករបស់របរប្រើប្រាស់ ដូចជាទូរស័ព្ទ ឬឧបករណ៍ផ្សេងៗទៀត។ ប្រសិនបើឧបករណ៍ត្រូវតែចែករំលែក ត្រូវធ្វើអោយប្រាកដថា ជូតសំអាតវា ដោយប្រើប្រដាប់ជូតសំឡាប់មេរោគ មុន និងក្រោយ ពេលចែករំលែក។
    - សង្កេតជានិច្ច នូវចម្ងាយការងាររបស់អ្នក នៃទំនាក់ទំនងជាមួយនឹងបុគ្គលិកផ្សេងទៀត។ ត្រូវរក្សាការ នៅដាច់ឆ្ងាយពីគ្នាដែលបានណែនាំ យ៉ាងតិចបំផុត ៦ ហ្វីត ពីអ្នកដទៃ លើកលែងតែការងារជាក់លាក់ ដែលតម្រូវអោយមានចំងាយតិចជាង ហើយត្រូវពាក់គម្របមុខ នៅពេលធ្វើការជិត ឬជាមួយអ្នកដទៃ។
    - សំឡាប់មេរោគចំពោះ ឬទៅលើវត្ថុ និងផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់ ដូចជាស្ថានីយការងារ, ក្តារចុច, ទូរស័ព្ទ, ដៃរទេះរុញ, ម៉ាស៊ីនផ្សេងៗ, ឧបករណ៍ចែករំលែកទាំងឡាយ និងប្រដាប់មូលកាន់តាមមាត់ទ្វារ។ នេះគួរតែត្រូវបានធ្វើរៀងរាល់ម៉ោង ក្នុងកំឡុងពេលម៉ោងធ្វើការ។
    - លើកទឹកចិត្តបុគ្គលិក អោយជំនួសការចាប់ដៃជាមួយនឹងទម្រង់ស្វាគមន៍នានា ដោយមានការប៉ះពាល់តិចបំផុតចំពោះអតិថិជន និងសមាជិកទាំងឡាយ។
- ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកទាំងអស់។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ☐ ថ្នាំសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖
- ☐ ទឹកផ្ញើអនាម័យដែសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖
- ☐ សាប៊ូ និងទឹក សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

## F. នីតិវិធី ចុងបញ្ចប់នៃវេន

- ☐ បុគ្គលិកមានការទទួលខុសត្រូវក្នុងការសំឡាប់មេរោគ ចំពោះឧបករណ៍ប្រើប្រាស់ បន្ទាប់ពីប្រតិបត្តិការរួច។ មានវត្ថុសំឡាប់មេរោគតាមស្ថានីយ៍ឧបករណ៍សំខាន់ៗ សំរាប់អោយបុគ្គលិកសំអាតឬជូតជំរះនូវឧបករណ៍នានា មុន និងក្រោយពេលប្រើ។
- ☐ តំរូវអោយបុគ្គលិកទាំងអស់ ត្រូវចាកចេញពីទ្រព្យសម្បត្តិភ្លាមៗ បន្ទាប់ពីចប់វេនការងារ របស់ពួកគេ។
- ☐ សមាជិកក្រុមនីមួយៗត្រូវបានរំលឹក អំពីសារៈសំខាន់នៃការឃ្លាតឆ្ងាយរាងកាយពីគ្នា ពេលចេញពីការងារ ក៏ដូចជាក្នុងកំឡុង ពេលបំពេញការងារ។

## G. ពិធីការ ត្រួតពិនិត្យ

- ☐ ការរួសរាយរាក់ទាក់, ប៉ុន្តែការប្រាស្រ័យទាក់ទងយ៉ាងម៉ឺងម៉ាត់ ជាមួយនឹងភ្ញៀវណាដែលរំលោភបំពានលើតំរូវការនៃ ពិធីការសុវត្ថិភាព គឺជាកត្តាចាំបាច់។ ភ្ញៀវទាំងឡាយ ត្រូវបានក្រើនរំលឹកថា រាល់ការបំពារបំពានណាមួយ នៃពិធីការសុវត្ថិភាពនៅឃ្លាតឆ្ងាយពីគ្នា នឹងបង្កនូវភាពអន្តរាយដល់ការបន្តនូវប្រតិបត្តិការ នៃជំនួញជួលសំភារៈកំសាន្តក្រៅផ្ទះ ក្នុងស្រុក។
- ☐ ភ្ញៀវណាម្នាក់, ដែលបដិសេធមិនគោរពតាមពិធីការសុវត្ថិភាពនានា បន្ទាប់ពីផ្តល់នូវការព្រមានម្តងរួចហើយនោះ ត្រូវបានស្នើសុំអោយចាកចេញ ពីទ្រព្យសម្បត្តិភ្លាម។

**វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបាន**

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

ដាក់វាយ នៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។

អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:

ឈ្មោះទំនាក់ទំនងអាជីវកម្ម: ______________________ លេខទូរស័ព្ទ: ______________________

កាលបរិច្ឆេទកែប្រែចុងក្រោយ: ______________________

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**